ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# អនុស្សរណៈនៃការយោគយល់គ្នា

រវាង

## ក្រសួងមហាផ្ទៃ និង អង្គការតម្លាភាពកម្ពុជា

ស្តីពី

## «ការរៀបចំ និងប្រព្រឹត្តទៅនៃសាលាអភិបាលកិច្ច ជំណាក់កាលទី២»

អនុវត្ត ឆ្នាំ ២០២១-២០២៤

## ១. ពិជ្ជភាពទូទៅ

អនុស្សរណៈនៃការយោគយល់គ្នានេះ ត្រូវបានរៀបចំឡើងក្នុងក្របខណ្ឌកិច្ចសហប្រតិបត្តិការការងារ រវាង**ក្រសួងមហាផ្ទៃ** និង**អង្គការតម្លាភាពកម្ពុជា** រយៈពេល៥ឆ្នាំ ដែលអនុវត្តពីឆ្នាំ២០២១ រហូតដល់ឆ្នាំ២០២៥ នៅក្រោមគម្រោង ***សាលាអភិបាលកិច្ច ដំណាក់កាលទី២*** ដែលបាន និងកំពុងអនុវត្តពីឆ្នាំ២០២០-២០២២។

## ២. សារចាន

រាជរដ្ឋាភិបាលកម្ពុជា បានបង្ហាញការប្ដេជ្ញាចិត្តយ៉ាងមោះមុតក្នុងការអភិវឌ្ឍប្រទេសជាតិឆ្ពោះទៅរកភាពរុងរឿង វិបុលភាព ឯកភាពជាតិ សន្តិភាព សាមគ្គីភាព និងសុខដុមរមនានៅក្នុងសង្គម តាមរយៈការអនុម័តច្បាប់ គោលនយោបាយ និងគោលការណ៍ណែនាំនានា សំដៅលើកកម្ពស់លទ្ធិប្រជាធិបតេយ្យ ការគោរពសិទ្ធិមនុស្ស ការពង្រឹងអភិបាលកិច្ចល្អ នីតិរដ្ឋ និងយុត្តិធម៌សង្គម។ ទន្ទឹមនេះ ដើម្បីសម្រេចបាននូវទិសដៅខាងលើ រាជរដ្ឋាភិបាលបាននិងកំពុងបន្តអនុវត្តយុទ្ធសាស្ត្រចតុកោណក្នុងដំណាក់កាលទី៤ (២០១៨-២០២៣) និងអនុវត្តផែនការអភិវឌ្ឍយុទ្ធសាស្ត្រជាតិ (២០១៩ - ២០២៣) និងពង្រឹងការអនុវត្តច្បាប់គ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ (២០០៨) និងច្បាប់គ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់(២០០១) ជាពិសេសការអនុវត្តកម្មវិធីជាតិ ១០ឆ្នាំ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យថ្នាក់ក្រោមជាតិ ឆ្នាំ២០១០ ដល់ឆ្នាំ២០១៩ និងពន្យារពេលដល់ឆ្នាំ២០២០ និងផែនការរយៈពេល១០ឆ្នាំបន្ទាប់ ដែលគ្រោងចាប់ពីឆ្នាំ២០២១ ដល់ឆ្នាំ២០៣០ ។ល។

ក្នុងស្មារតីនេះ រាជរដ្ឋាភិបាលបានផ្ដោតការយកចិត្តទុកដាក់ជាអាទិភាពលើការពង្រឹងអភិបាលកិច្ច និងសមត្ថភាពស្ថាប័នរដ្ឋ សំដៅបង្កើនប្រសិទ្ធភាពនៃសេវាសាធារណៈ និងកែលម្អបរិយាកាសវិនិយោគ តាមរយៈ (១)-ការបន្តអនុវត្តការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដើម្បីធានាយុត្តិធម៌សង្គម ព្រមទាំងលើកស្ទួយសិទ្ធិរបស់ប្រជាពលរដ្ឋ តម្លាភាព សុចរិតភាព និងគណនេយ្យភាព (២)-ការបន្តអនុវត្តកំណែទម្រង់រដ្ឋបាលសាធារណៈ ការកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ព្រមទាំងពង្រឹងស្ថាប័នត្រួតពិនិត្យដើម្បីបង្ខិតសេវាសាធារណៈឱ្យជិតប្រជាជន លើកកម្ពស់កិច្ចដំណើរការប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងធានាបាននូវតុល្យភាពក្នុងការអនុវត្តអំណាច។

ដោយយល់ឃើញថា កត្តាសមត្ថភាព ចំណេះដឹង ជំនាញ និងសុចរិតភាព ជាកត្តាចម្បងសម្រាប់លើកកម្ពស់អភិបាលកិច្ច និងការពង្រឹងប្រសិទ្ធភាពក្នុងការផ្ដល់សេវាសាធារណៈ អង្គការតម្លាភាពកម្ពុជាបានគាំទ្រកម្មវិធីកសាងសមត្ថភាពដល់មន្ត្រីក្រោមឱវាទក្រសួងមហាផ្ទៃ តាមរយៈការបង្កើតគម្រោង «**សាលាអភិបាលកិច្ច ដំណាក់កាលទី១ ឆ្នាំ២០១៦ រហូតដល់ឆ្នាំ ២០២០**»។ រយៈពេល៥ឆ្នាំកន្លងទៅនេះ អង្គការតម្លាភាពកម្ពុជាបានទទួលនូវការគាំទ្រយ៉ាងពេញទំហឹង និងកិច្ចសហប្រតិបត្តិការយ៉ាងស្អិតរមួតពីនាយកដ្ឋានសុចរិតភាព និងអភិបាលកិច្ច ក្នុងការអនុវត្តកម្មវិធីបណ្ដុះបណ្ដាលស្ដីពី «**អភិបាលកិច្ចល្អ**» ដល់មន្ត្រីក្រសួងមហាផ្ទៃ និងមន្ត្រីដែល

ជាអ្នកផ្តល់សេវានៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ ភាពជោគជ័យក្នុងការអនុវត្តគម្រោង «**សាលាអភិបាលកិច្ចដំណាក់កាលទី១**» និងដោយយល់ឃើញថា តម្រូវការសម្រាប់ការបណ្តុះបណ្តាលសមត្ថភាពមន្ត្រីផ្តល់សេវារដ្ឋបាលថ្នាក់ក្រោមជាតិនៅតែមានភាពចាំបាច់ ក្នុងការពង្រឹងគុណភាពនៃការផ្តល់សេវាសាធារណៈប្រកបដោយតម្លាភាព គណនេយ្យភាព បរិយាប័ន្ន និងឆ្លើយតបតម្រូវការប្រជាពលរដ្ឋ អង្គការតម្លាភាពកម្ពុជាសម្រេចបន្តកិច្ចសហប្រតិបត្តិការរយៈពេល៥ឆ្នាំទៀត គិតចាប់ពីឆ្នាំ២០២១ រហូតដល់ឆ្នាំ២០២៥ ដើម្បីជួយគាំទ្ររាជរដ្ឋាភិបាលសម្រេចឱ្យបាននូវចក្ខុវិស័យរបស់រាជរដ្ឋាភិបាល សម្រាប់កំណែទម្រង់តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងកម្មវិធីកំណែទម្រង់វិស័យរដ្ឋបាលសាធារណៈ ព្រមទាំងពង្រឹងការផ្តល់សេវាសាធារណៈនៅថ្នាក់ក្រោមជាតិឱ្យកាន់តែមានប្រសិទ្ធភាព និងប្រកបដោយគុណភាព។

## ៣. ក្រសួងមហាផ្ទៃ

ក្រសួងមហាផ្ទៃមានបេសកកម្មដឹកនាំ គ្រប់គ្រងរដ្ឋបាលដែនដីគ្រប់ថ្នាក់ លើវិស័យនយោបាយរដ្ឋបាល គ្រប់ គ្រងកម្លាំងនគរបាលជាតិលើវិស័យសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គមក្នុងព្រះរាជាណាចក្រកម្ពុជា។ ក្រសួងមហាផ្ទៃមានតួនាទី និងភារកិច្ចចម្បងៗជាអាទិ៍៖ ដឹកនាំ សម្របសម្រួល បញ្ជាកម្លាំងគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិឱ្យអនុវត្តមុខងារត្រឹមត្រូវតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ការងារផ្តល់សេវារដ្ឋបាលប្រកបដោយគុណភាព តម្លាភាព ប្រសិទ្ធភាព និងឆ្លើយតបទាន់ពេលវេលា ការងារសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ ការងារអត្តសញ្ញាណកម្ម ការងារសញ្ជាតិ ការងារអន្តោប្រវេសន៍ ការងារជនភៀសខ្លួន ការងារពន្ធនាគារ ។ល។ ព្រមទាំងទទួលអនុវត្តភារកិច្ច និងសិទ្ធិផ្សេងៗទៀតដែលរាជរដ្ឋាភិបាលប្រគល់ជូន។

នៅក្នុងភារកិច្ចនេះ ក្រសួងមហាផ្ទៃ មានតួនាទី និងភារកិច្ចយ៉ាងសំខាន់ក្នុងការបន្តជំរុញដំណើរការប្រជាធិបតេយ្យភាវូបនីយកម្មទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ទាំងក្នុងវិស័យនយោបាយ សេដ្ឋកិច្ច និងសង្គមកិច្ចឱ្យឈានឡើងឥតឈប់ឈរនៅក្នុងបរិការណ៍របស់កម្ពុជា ទៅលើមូលដ្ឋាននៃការបន្តលើកកម្ពស់នីតិរដ្ឋ ការលើកស្ទួយសិទ្ធិសេរីភាពគ្រប់យ៉ាងរបស់ប្រជាពលរដ្ឋ ការធានានូវសកម្មភាពដោយសេរីរបស់គណបក្សនយោបាយ ការបោះឆ្នោតដោយសេរី និងយុត្តិធម៌ ព្រមទាំងការលើកកម្ពស់សុខុមាលភាពសង្គម។

ការពង្រឹងកិច្ចដំណើរការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ បង្ហាញឱ្យឃើញនូវកំណែទម្រង់ដ៏មានសារៈសំខាន់មួយនៃរចនាសម្ព័ន្ធគ្រប់គ្រងរបស់រាជរដ្ឋាភិបាលកម្ពុជា។ គោលដៅសំខាន់នៃកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ គឺការលើកកម្ពស់សុខុមាលភាពរបស់ប្រជាពលរដ្ឋ (ទាំងសិទ្ធិ និងជីវភាពរស់នៅ) ការលើកកម្ពស់សមភាពរវាងប្រជាពលរដ្ឋនៅក្នុងសហគមន៍ និងការធានានូវយុត្តិធម៌ក្នុងការទទួលបានសេវាសាធារណៈ។ ការកែលម្អ និងការផ្លាស់ប្តូរឥរិយាបថនៃភាពជាតំណាង ព្រមទាំងការផ្តល់ឱកាសចូលរួមជាមតិយោបល់ ជាសិទ្ធិដល់ប្រជាពលរដ្ឋកាន់តែទូលំទូលាយក្នុងការប្រាស្រ័យទាក់ទង

ជាមួយតំណាងរបស់ខ្លួន និងការជំរុញឱ្យមានគណនេយ្យភាពកាន់តែខ្លាំងឡើងរបស់ក្រុមប្រឹក្សា និងមន្ត្រីនានាចំពោះប្រជាពលរដ្ឋ ។ ការបង្កើននូវ**មូលធនសង្គម** និងការផ្សារភ្ជាប់គ្នានៅសហគមន៍ គឺជាធាតុចូលដ៏មានសារៈសំខាន់ និងមានប្រសិទ្ធភាពក្នុងដំណើរការអភិវឌ្ឍសង្គមជាតិ ឱ្យបានរុងរឿងគ្រប់វិស័យ គ្រប់ជ្រុងជ្រោយទៅអនាគត។

របនាសម្ព័ន្ធអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យនៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបានរៀបចំឡើងវិញស្របតាមគោលការណ៍ដែលបានចែងក្នុងច្បាប់រៀបចំអង្គការ កម្មវិធីជាតិរយៈពេល១០ឆ្នាំ និងផែនការអនុវត្តរយៈពេល៣ឆ្នាំនៃកម្មវិធីជាតិនេះ។ ការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ឃុំ សង្កាត់ក៏បានបង្ហាញ នូវលទ្ធផលជាវិជ្ជមានគួរឱ្យកត់សម្គាល់ក្នុងការលើកកម្ពស់លទ្ធិប្រជាធិបតេយ្យនៅមូលដ្ឋាន ការពង្រឹងអភិបាលកិច្ចល្អ ការកែលម្អគុណភាពនៃជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន។ **កំណែទម្រង់ វិមជ្ឈការ និងវិសហមជ្ឈការ ពិតជាបានរួមចំណែកដល់ការពង្រឹងលទ្ធិប្រជាធិបតេយ្យនៅមូលដ្ឋាន** ការធ្វើឱ្យប្រសើរឡើងនូវជីវភាពរបស់ប្រជាជន ការពង្រឹងភាពជាអ្នកដឹកនាំនៅមូលដ្ឋាន ទាំងបុរស ទាំងស្ត្រី និងក៏បានធ្វើឱ្យមានការកែលម្អនូវការផ្តល់សេវាសាធារណៈនៅមូលដ្ឋានផងដែរ។

ក្រសួងមហាផ្ទៃបាន និងបន្តកិច្ចសហការជាមួយក្រសួង ស្ថាប័ននានា ជំរុញការអនុវត្តកម្មវិធីកំណែទម្រង់សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ឱ្យបានទទួលលទ្ធផលជាវិជ្ជមានបន្ថែមទៀត។

## ៤. នាយកដ្ឋានសុចរិតភាព និងអភិបាលកិច្ច នៃក្រសួងមហាផ្ទៃ

**នាយកដ្ឋានសុចរិតភាព និងអភិបាលកិច្ច** មានតួនាទីធ្វើជាសេនាធិការជូនអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុងលើការងារចម្បងៗរួមមាន៖ ធ្វើការទំនាក់ទំនង និងសម្របសម្រួលទូទៅ ពង្រឹងការកសាងសមត្ថភាពស្ថាប័ន និងការបណ្តុះបណ្តាលធនធានមនុស្ស ពង្រឹងកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ ធ្វើការសិក្សាស្រាវជ្រាវអំពីសុចរិតភាព និងអភិបាលកិច្ចល្អ និងផ្សព្វផ្សាយព័ត៌មានទាក់ទងនឹងសុចរិតភាព និងអភិបាលកិច្ចល្អ ដល់អង្គភាពនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលស្ថិតនៅក្រោមឱវាទក្រសួងមហាផ្ទៃ និងមានភារកិច្ចដូចខាងក្រោម៖

- ធ្វើផែនការយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍធនធានអភិបាលកិច្ចប្រចាំឆ្នាំ និង៣ឆ្នាំរំកិល ផែនការចំណាយថវិកាប្រចាំឆ្នាំ និងផែនការយុទ្ធសាស្ត្រថវិកា៣ឆ្នាំរំកិលរបស់នាយកដ្ឋាន
- សិក្សាស្រាវជ្រាវ និងបណ្តុះបណ្តាលដល់មន្ត្រីសាធារណៈ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ពាក់ព័ន្ធអភិបាលកិច្ច គណនេយ្យភាពសង្គម សុចរិតភាព នៃរដ្ឋបាលសាធារណៈ
- ផ្សព្វផ្សាយដល់សង្គមស៊ីវិល កសាងភាពជាដៃគូ ដើម្បីអោយសង្គមស៊ីវិលបានចូលរួមក្នុងកិច្ចការអភិបាលកិច្ច គណនេយ្យភាពសង្គម សុចរិតភាព នៃរដ្ឋបាលសាធារណៈ
- ផ្តល់ការណែនាំផ្នែកបច្ចេកទេស និងសម្របសម្រួលពាក់ព័ន្ធនឹងការរៀបចំកម្មវិធី សៀវភៅមេរៀន សម្ភារ និងព័ត៌មាននានាសម្រាប់ការអភិវឌ្ឍសមត្ថភាព

- សហការជាមួយស្ថាប័ន និងអង្គភាពនាយកដ្ឋានពាក់ព័ន្ធនានា ដើម្បីលើកកម្ពស់ការអភិវឌ្ឍធនធានអភិបាលកិច្ច
- ធ្វើការផ្សព្វផ្សាយបញ្ជ្រាបការយល់ដឹងអំពី គោលការណ៍អភិបាលកិច្ចល្អជូនប្រជាពលរដ្ឋគ្រប់មូលដ្ឋាន តាមរយៈការធ្វើវេទិកាសាធារណៈ ដែលមានការចូលរួមពីអាជ្ញាធរ សមត្ថកិច្ចមូលដ្ឋានតាមលំដាប់ថ្នាក់
- ធ្វើការបណ្តុះបណ្តាលគ្រូបង្គោលពាក់ព័ន្ធនឹងការពង្រឹងចំណេះដឹង និងសមត្ថភាពលើការងារអភិបាលកិច្ច ។ល។

## ៥. នាយកដ្ឋានមុខងារ និងធនធាននៃក្រសួងមហាផ្ទៃ

**នាយកដ្ឋានមុខងារ និងធនធាន** មានតួនាទីជាសេនាធិការឱ្យអគ្គនាយកដ្ឋានរដ្ឋបាលនៃក្រសួងមហាផ្ទៃ លើការងារផ្ទេរមុខងារ ធនធាន និងគាំទ្រការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ **នាយកដ្ឋានមុខងារ និងធនធាន** មានភារកិច្ចដូចខាងក្រោម ៖

- រៀបចំក្របខណ្ឌគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តនានាសម្រាប់ការផ្ទេរមុខងារ និងធនធានឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ
- រៀបចំក្របខណ្ឌគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ព្រមទាំងយន្តការ បែបបទ និងនីតិវិធីនានាសម្រាប់គាំទ្រការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- សម្របសម្រួល និងគាំទ្រដល់ក្រសួង ស្ថាប័នក្នុងកិច្ចដំណើរការផ្ទេរមុខងារ និងធនធានដល់រដ្ឋបាលថ្នាក់ក្រោមជាតិ
- តាមដាន និងត្រួតពិនិត្យលើការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាបាននូវគោលការណ៍តម្លាភាព គណនេយ្យភាព ប្រសិទ្ធភាព និងការចូលរួមរបស់ប្រជាពលរដ្ឋ
- សហការរៀបចំប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃលើការបំពេញមុខងារដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ
- សិក្សា និងរៀបចំយន្តការសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ធ្វើការសម្រុះសម្រួល និងដោះស្រាយពាក្យបណ្តឹងនានានៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- តាមដាន ត្រួតពិនិត្យ វាយតម្លៃ និងគាំទ្រលើយន្តការនៃការសម្រុះសម្រួល និងដោះស្រាយពាក្យបណ្តឹងនានានៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

## ៦. អង្គការតម្លាភាពកម្ពុជា

**អង្គការតម្លាភាពកម្ពុជា** ត្រូវបានបង្កើតឡើងនៅខែកក្កដា ឆ្នាំ២០១០ និងធ្វើសកម្មភាពជាមួយអ្នកពាក់ព័ន្ធនានា ជាបុគ្គល ឬស្ថាប័ននៅគ្រប់កម្រិត រួមមាន៖ រដ្ឋាភិបាល សង្គមស៊ីវិល វិស័យឯកជន ប្រព័ន្ធផ្សព្វផ្សាយ និងស្ថាប័នសាធារណៈផ្សេងៗទៀត ដើម្បីរួមចំណែកអភិវឌ្ឍសមត្ថភាពស្ថាប័ន លើកកម្ពស់សុចរិតភាព និងប្រយុទ្ធប្រឆាំងអំពើពុករលួយនៅកម្ពុជា ។

កន្លងមក **អង្គការតម្លាភាពកម្ពុជា** បានទទួលការគាំទ្របច្ចេកទេស ធនធាន និងថវិកាពីដៃគូអភិវឌ្ឍន៍ពីប្រទេសអ្នកផ្តល់ជំនួយនានាជាច្រើន ដើម្បីលើកកម្ពស់អភិបាលកិច្ចល្អ អភិវឌ្ឍសមត្ថភាពស្ថាប័ន និងចូលរួមបង្កើនការយល់ដឹងពីប្រព័ន្ធសុចរិតភាពស្ថាប័ន តាមរយៈការបង្កើនតម្លាភាព គណនេយ្យភាព និងនីតិរដ្ឋ ។

បច្ចុប្បន្ននេះ **អង្គការតម្លាភាពកម្ពុជា** កំពុងអនុវត្តផែនការយុទ្ធសាស្ត្ររយៈពេល៣ឆ្នាំ (ចាប់ពីឆ្នាំ២០២០-២០២២) ដែលមានទិសដៅរួមចំណែកអភិវឌ្ឍធនធានមនុស្ស បង្កើនសមត្ថភាពស្ថាប័ននៅគ្រប់កម្រិត ទាំងរដ្ឋ និងឯកជន ក្រុមជនងាយរងគ្រោះ ជាពិសេសយុវជន ព្រមទាំងពង្រឹងការផ្តល់សេវានៅថ្នាក់ក្រោមជាតិឱ្យមានតម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាពថែមទៀត។ កន្លងមក អង្គការតម្លាភាពកម្ពុជាបានធ្វើកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នរដ្ឋមួយចំនួនមានដូចជា ក្រសួងរ៉ែ និងថាមពល ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋសភា អគ្គនាយកដ្ឋានពន្ធដារ ព្រមទាំង វិស័យឯកជន និងអង្គការសង្គមស៊ីវិលជាច្រើននៅកម្ពុជា។

## ៧. គោលបំណងរួមនៃអនុស្សរណៈនៃការយោគយល់គ្នា

១. ពង្រីកកិច្ចសហប្រតិបត្តិការជាមួយក្រសួងមហាផ្ទៃ និងស្ថាប័ននានាក្រោមឱវាទក្រសួងមហាផ្ទៃ
២. រួមចំណែកអភិវឌ្ឍសមត្ថភាពស្ថាប័នរដ្ឋ និងមិនមែនរដ្ឋ លើវិស័យអភិបាលកិច្ច ប្រព័ន្ធសុចរិតភាព និងគណនេយ្យភាពសង្គម ប្រកបដោយចីរភាព
៣. ចែករំលែកធនធាន (បច្ចេកទេស ចំណេះដឹង បទពិសោធន៍ សម្ភារ ថវិកា ។ល។)
៤. រួមគ្នាធ្វើការសិក្សាស្រាវជ្រាវ តាមបែបចូលរួមលើប្រធានបទទាក់ទងនឹងការលើកកម្ពស់អភិបាលកិច្ចល្អ ការពង្រឹងអភិបាលកិច្ចមូលដ្ឋាន គណនេយ្យភាពសង្គម ។ល។
៥. បង្កើនប្រសិទ្ធភាពនៃអភិបាលកិច្ច និងការផ្តល់សេវាសាធារណៈនៅគ្រប់កម្រិត និង
៦. ចូលរួមសហការ និងជំរុញយន្តការដោះស្រាយបណ្តឹងពាក់ព័ន្ធនឹងគណនេយ្យភាពនៅគ្រប់កម្រិត។

## ៨. គោលបំណងនៃអនុស្សរណៈនៃការយោគយល់គ្នា

ទី១. ផ្តួចផ្តើម និងផ្តល់វគ្គបណ្តុះបណ្តាលគ្រូបង្គោលដល់មន្ត្រីក្រសួង និងផ្តល់វគ្គបណ្តុះបណ្តាលដល់ថ្នាក់ដឹកនាំ និងមន្ត្រីផ្តល់សេវាសាធារណៈនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីរួមចំណែកពង្រឹងការផ្តល់សេវានៅរដ្ឋបាល ថ្នាក់ក្រោមជាតិឱ្យកាន់តែមានតម្លាភាព គណនេយ្យភាព បរិយាប័ន្ន និងប្រសិទ្ធភាពថែមទៀត។

ទី២. ចូលរួមពង្រឹងការអនុវត្តយន្តការសម្រុះសម្រួល និងដោះស្រាយពាក្យបណ្តឹងនានានៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីជាធាតុចូលក្នុងការពង្រឹងយន្តការផ្តល់សេវារបស់រដ្ឋបាលក្រោមជាតិ ឱ្យកាន់តែមានតម្លាភាព គណនេយ្យភាព បរិយាប័ន្ន និងប្រសិទ្ធភាព ព្រមទាំងប្រកបដោយការចូលរួមពីប្រជាពលរដ្ឋ។

## ៩. តួនាទី និងការទទួលខុសត្រូវរបស់ភាគីទាំងពីរ

ដោយមើលឃើញពីសក្តានុពល និងភាពស្របគ្នាអំពីទស្សនវិស័យ បេសកកម្ម ផែនការយុទ្ធសាស្ត្ររបស់ក្រសួងមហាផ្ទៃ និងអង្គការតម្លាភាពកម្ពុជា ភាគីទាំងពីរបានឯកភាពអនុវត្តនូវសកម្មភាពរួមគ្នាមួយចំនួនដូចតទៅ ៖

### ក. ក្រសួងមហាផ្ទៃ

- ផ្តល់ការកិច្ចជូននាយកដ្ឋានសុចរិតភាព និងអភិបាលកិច្ច នៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង និងនាយកដ្ឋានមុខងារ និងធនធាន នៃអគ្គនាយកដ្ឋានរដ្ឋបាល ជាភ្នាក់ងារអនុវត្តគម្រោង
- ជួយផ្តល់កិច្ចសម្របសម្រួលជាទូទៅគ្រប់លំដាប់ថ្នាក់ និងគ្រប់កម្រិតដើម្បីជានាឱ្យការអនុវត្តគម្រោងនេះប្រព្រឹត្តិទៅបានរលូន និងមានប្រសិទ្ធភាពខ្ពស់ សម្រេចបានតាមផែនការកំណត់
- ផ្តល់ទីតាំង និងចាត់តាំងបុគ្គលិក មន្ត្រីចូលរួមបំពេញការងារ និងអនុវត្តគម្រោងប្រកបដោយឆន្ទៈ និងការប្តេជ្ញាចិត្តខ្ពស់
- ចូលរួមចំណែកផ្តល់ធនធាន (ជាមធ្យោបាយ សម្ភារ និងថវិកា) សម្រាប់ដំណើរការអនុវត្តគម្រោង និងការបណ្តុះបណ្តាល ។

### ខ. អង្គការតម្លាភាពកម្ពុជា

- ផ្តល់ការគាំទ្រផ្នែកបច្ចេកទេស ហិរញ្ញវត្ថុ និងប្រឹក្សាយោបល់ក្នុងការអនុវត្តសកម្មភាពគម្រោងឱ្យបានល្អប្រសើរ
- ទំនាក់ទំនងជាមួយអ្នកពាក់ព័ន្ធ និងអង្គការដៃគូ ក្នុងការស្វែងរកថវិកាគាំទ្រគម្រោងសម្រាប់ឆ្នាំ២០២៣ រហូតដល់ឆ្នាំ២០២៥
- ផ្តល់អ្នកជំនាញការឯកទេស សម្រាប់ជួយផ្នែកបច្ចេកទេសក្នុងការរៀបចំចងក្រងឯកសារនានា (គោលការណ៍ណែនាំ កម្មវិធីសិក្សា លក្ខណវិនិច្ឆ័យការជ្រើសរើសសិក្ខាកាម ផលិតឯកសារបណ្តុះបណ្តាល ។ល។) និងចូលរួមសហការការអនុវត្តគម្រោងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ។

## ១០. ការអនុវត្តអនុស្សរណៈនៃការយោគយល់គ្នា

អនុស្សរណៈនៃការយោគយល់គ្នានេះ ប្រព្រឹត្តទៅបានដោយផ្អែកទៅលើគម្រោងផែនការសកម្មភាពអនុវត្តលម្អិតរួមមាន៖ ឯកសារស្តីពី (១)-កិច្ចព្រមព្រៀងសហប្រតិបត្តិការ (២)- ផែនការសកម្មភាព និងថវិកា៣ឆ្នាំ (២០២០ ដល់ ២០២២) និង (៣)- ក្របខណ្ឌលទ្ធផល (Result Framework ២០២០ ដល់ ២០២២) ដែលបានរៀបចំ និងយល់ព្រមដោយភាគីទាំងពីរ។

## ១១. បទប្បញ្ញត្តិចុងក្រោយ និងការបកស្រាយឯកសារ

- អនុស្សរណៈនៃការយោគយល់គ្នានេះ រៀបចំឡើងជាភាសាខ្មែរ និងជាភាសាអង់គ្លេស ដែលមានតម្លៃស្មើគ្នា។
- អនុស្សរណៈនៃការយោគយល់គ្នានេះ អាចស្នើធ្វើការកែតម្រូវ ឬលុបចោលបានលុះត្រាតែមានការជូនដំណឹងជាលាយលក្ខណ៍អក្សរពីភាគីណាមួយក្នុងរយៈពេល បី (៣) ខែជាមុន។

ថ្ងៃព្រហស្បតិ៍ ៨កើត ខែមាឃ ឆ្នាំជូត ទោស័កព.ស ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី២១ ខែមករា ឆ្នាំ២០២១

| តំណាងក្រសួងមហាផ្ទៃ | តំណាងអង្គការសម្ភាពកម្ពុជា |
|---|---|
| ឯកឧត្តម ជិ ច័ន្ទផល | លោកស្រី ប៉ុក ម៉ារីណា |
| រដ្ឋលេខាធិការ | តំណាងក្រុមប្រឹក្សាភិបាល |